# សំណើចេញ

អាជ្ញាធរកណ្តាលវាយតម្លៃ និងកំណត់អំពីលក្ខខណ្ឌនៃការបញ្ជូនសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជាទៅរដ្ឋទទួលសំណើដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ (មាត្រា៥(៤))

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធអាចស្នើសុំការជួយផ្នែកច្បាប់ពីរដ្ឋបរទេសតាមរយៈអាជ្ញាធរកណ្តាល។ (មាត្រា៣៥)
អាជ្ញាធរកណ្តាលទទួលសំណើដែលបានស្នើសុំដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៥(២))

អាជ្ញាធរកណ្តាលត្រូវពិចារណាលើភាពសមស្របនៃសំណើដោយពិចារណាលើបទប្បញ្ញត្តិ ព័ត៌មានលម្អិត អង្គហេតុ និងឯកសារពាក់ព័ន្ធ ហើយត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចដែលដាក់សំណើអំពីការសម្រេចរបស់ខ្លួន។ ក្នុងករណីចាំបាច់ អាជ្ញាធរកណ្តាលអាចស្នើសុំការសម្រេច ពីរាជរដ្ឋាភិបាលមុននឹងអនុវត្តនីតិវិធីបន្ត។ (មាត្រា៣៥)

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបំពេញសំណុំបែបបទនៃការស្នើសុំជំនួយដែលនឹងត្រូវកំណត់ ដោយអាជ្ញាធរកណ្តាល។ (មាត្រា៣៦)

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធមិនបានបំពេញសំណុំបែបបទនៃការស្នើសុំជំនួយដែលនឹងត្រូវកំណត់ដោយអាជ្ញាធរកណ្តាល។

អាជ្ញាធរកណ្តាលអាចស្នើសុំនូវព័ត៌មានបន្ថែម ដើម្បីធានាថាសំណើសុំជំនួយនោះនឹងអាចទទួលយកដោយរដ្ឋទទួលសំណើ។ (មាត្រា៣៦)

អាជ្ញាធរកណ្តាលបញ្ជូនសំណើនោះទៅកាន់រដ្ឋទទួលសំណើ។ (មាត្រា៥(២))

អាជ្ញាធរកណ្តាលតាមដាននិងទាក់ទងជាមួយអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើដើម្បីពន្លឿនការអនុវត្តសំណើរបស់ព្រះរាជាណាចក្រកម្ពុជា។ (មាត្រា៥(៦))

អាជ្ញាធរកណ្តាលទទួលលទ្ធផលនៃការអនុវត្តសំណើពីរដ្ឋទទួលសំណើ និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

អាជ្ញាធរអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលធ្វើសំណើ មិនត្រូវប្រើប្រាស់ ឬទម្លាយព័ត៌មាន ឬភស្តុតាងដែលផ្តល់ដោយរដ្ឋទទួលសំណើ ក្នុងគោលបំណងក្រៅពីការកំណត់នៅក្នុងសំណើ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋទទួលសំណើឡើយ។ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលធ្វើសំណើ ត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បីរក្សាព័ត៌មានសម្ងាត់និងភស្តុតាងដែលផ្តល់ដោយរដ្ឋទទួលសំណើ លើកលែងតែភស្តុតាង និងព័ត៌មាន ដែលចាំបាច់សម្រាប់គោលបំណងដែលបានកំណត់នៅក្នុងសំណើ។ (មាត្រា៣៧)